Khmer Story Lovers

# បណ្ដាំមរណៈ

— ទីតាំងការនៃក្រុមអ្នកនិពន្ធមាតុភូមិផ្ទះលេខ ២៧ ផ្លូវលេខ ២៥៥ អ៊ីឡូត៍លេខ ២៨ បឹងកេងកង សង្កាត់លេខ ៤ ក្រុងភ្នំពេញ —

## ប្រលោមលោកចេញផ្សាយរៀងរាល់ថ្ងៃ



ស៊ីផានលាន់មាត់សរសើរ :

-មែន , ស្នៀតនេះពូកែអស្ចារ្យ, បន្តិចទៅឆ្វេង បន្តិចទៅស្ដាំ ម្ដងខាងលើម្ដងខាងក្រោម។ បើញាប់ ម្លឹងៗ សត្រូវការពារខ្លួនម្ដេចកើត ?

-នេះឯងជាចំណុចសំខាន់នៃស្នៀតខ្ញុំ ដើម្បីឲ្យបងសាន្តាសសត្រូវនោះណា! ឆាកប្រយុទ្ធនីមួយៗ អាចបានគ្រោះថ្នាក់ នៅពេលអាវុធប៉ះទង្គិចគ្នាដែលគូសត្រូវបញ្ចេញកម្លាំងធាតុ ដើម្បីវាយសង្កត់យកឈ្នះ តាញ់តែរៀងខ្លួន ។ ពេលនោះ ដោយរំភ្លុកទៅលើ ភាពទន់ភ្លន់ និងរហ័សរហួនរបស់ស្នៀត "ស្ទង់ឆ្វេងស្ទាបស្ដាំ"នេះ បងអាចបញ្ចៀសបានពីការប្រើកម្លាំងធាតុ ប្រទល់គ្នា ដែលជាការណ៍មួយផ្ដល់នូវគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរ ដល់ គូបដិបក្ខម្ខាងៗ ម្យ៉ាងទៀតស្នៀតនេះ គ្មានលក្ខណៈ វាយលុក ប្រហារ ឲ្យគូប្រយុទ្ធរបួសបានទេ វាគ្រាន់តែជាស្នៀតដែលបោកបញ្ឆោត និងកំភ្លើញគូប្រយុទ្ធតែប៉ុណ្ណោះ

និយាយចប់អាស៊ីវសួរបន្ត ៖

-បងដឹងទេ ,ហេតុដូចម្ដេចបានជា ស្នៀតនេះមានឈ្មោះ ដូច្នេះ ?

អ្នកកម្លោះរៀនឡើងមុខ ក្រហមងាំងឆ្អៅក្នុកស្លី ... ឆ្លើយទាំងក់ទុប ៖

- អឺ...អឺ...

អ្នកប្រែសម្រួល ៖ អ.គឹមសារឿ

តម្លៃ

ផ្សាយចេញពីក្រុមអ្នកនិពន្ធ
«មាតុភូមិ»
ភ្នំពេញ
លេខ ២១

នាយពោលមិនបានព្រោះមិនយល់ន័យហើយមិនចាំពាក្យថ្មីនេះផែន ។ អាស៊ីវបន្តវាចា :

-បងវិលតែរវើរវាយទៅណា . . . ណ្ហើយ ! បែរមុខទៅខាងណោះម្តង, កុំមើលមុខខ្ញុំទៀត

សំដីនេះគឺអាស៊ីវចង់កំប្លែងជាមួយនាយសោះ, តែមាណពជាបុរសស្លូតបូតសុភាពរាបសាណាស់ ហើយល្ងង់ទៀតក៏បែរមុខពីនាងភ្លាមតាមបញ្ជា ។ នាងក្រមុំញញឹមៈ

-ស្នៀតនេះស្ទង់ឆ្វេងស្តាបស្តាំ ។ អ្នកគ្រូនិយមកាលរូបតែងចង់បានកិត្តិយសកេរ្តិ៍ឈ្មោះណាស់ បើអ្នកក្លាហានល្បីល្បាញម្នាក់ត្រូវបងវាយរបួសក្រោកមិនរួចអ្នកនោះលំបាកចិត្តណាស់, បើចាញ់ក្នុងមួយឬពីរស្នៀតគេព្រួយជាងចាញ់បងក្នុងរវាងប្អូនដប់ស្នៀតទៅទៀត ។ ហេតុនេះពេលប្រយុទ្ធត្រូវទុកផ្លូវខ្លះឲ្យគេដកថយផង គឺថាកាលណាឈ្នះហើយបងត្រូវសំដែងស្នៀតស្ទង់ឆ្វេងស្តាបស្តាំ សត្រូវច្រឡំភ្នែកមើលមិនទាន់ ។ ពេលនោះបងថយក្រោយពីរជំហានដកអាវុធចេញប្រមូលកម្លាំងកាយទុកដដែល, អ្នកដែលនៅក្រៅវង្វង់ប្រយុទ្ធឥតដឹងនរណាឈ្នះឬនរណាចាញ់ទេ បានសេចក្តីថា: បងទុកមុខទុកមាត់ឲ្យសត្រូវមួយខណៈ ។ ប្រសិនបើបង ៈពោលពាក្យគួរសមថែមមួយម៉ាត់ទៀតថា: "លោកមានយុទ្ធសិល្បៈខ្ពង់ខ្ពស់គួរឲ្យស្ញើចណាស់ , ថ្ងៃនេះ បើងវាយ ឈ្នះមិនចាញ់ ល្មមឈប់ប្រកួត ហើយសុំចងចិត្តនឹងគ្នាដោយស្មោះស្ម័គ្រ!" . . ។

អាស៊ីវនិយាយចប់ងាកមកសួរមាណព :

- បងបានយល់យ៉ាងណាដែរ ?

ស៊ីផាននឹកគិតថា តាំងពីចុះពីភ្នំបានមក នាយជួបនាកប្រយុទ្ធសាហាវៗខ្លះៗ ។ រីតែរាល់ការប្រយុទ្ធទាំងនោះមានករណីខ្លះជាការបន្ទំចិត្ត ដែលដុះយពីសតិសម្បជញ្ញៈនាយទាំងស្រុង ។ ម្យ៉ាងទៀត , អ្នកដែលបានបង្ហាត់បង្រៀននាយក៏គ្មានគោលគំនិតល្អត្រឹមត្រូវដែរ ។ ពិតមែនតែនៅក្នុងការប្រកួត , នាយគ្មានគោលបំណងនឹងធ្វើឲ្យរបួស ឬសម្លាប់មនុស្ស តែករណីខ្លះលទ្ធផលវាបាចឲ្យផ្ទុយវិញ , ឥឡូវមកឮអាស៊ីវទូន្មាននាយដូច្នេះ នាយងក់ក្បាលសរសើរ :

- នាងនិយាយត្រូវណាស់ !

- បើអីចឹង , សុំបងសម្តែងស្នៀតនេះសារឡើងវិញមើល៍ !

ស៊ីផានងក់ក្បាល ហើយចាប់សំដែងស្នៀតស្ទង់ឆ្វេងស្តាបស្តាំ ពីដើមដល់ចប់ត្រឹមត្រូវឥតខ្ចោះ - - ។

អាស៊ីវពោលទាំងរំភើ:

- ល្អណាស់ ! គ្មានក្មេងស្រីណាទេ ។

មាណពសំរែងចប់ដើរមកអង្គុយក្បែរនាងហើយកែកាយ ស្រាប់តែនាងក្រមុំដកដង្ហើមធំ :

-ខ្ញុំបន្ទាក់ស្នៀតស៊ុំទេស្ពាបស្ដាំនេះចេះហើយ, សុំបងកុំប្រាប់លោកយាយណា !

-មែនហើយ, ខ្ញុំមិននិយាយទេ ខ្ញុំដឹងថាលោកយាយច្បាស់ជាមិនសប្បាយចិត្ត ។

ហេតុអ្វីបងដឹងច្បាស់ថា លោកយាយមិនសប្បាយចិត្ត ?

-ព្រោះនាងមិនមែនជាសិស្សក្រុមព្រះអាទិត្យហើយខ្ញុំជាសិស្សឡូង, បើគាត់បន្ទាត់ខ្ញុំលោកយាយមិនសប្បាយចិត្តទេ ។

អាស៊ីវញញឹម :

ក្រុមព្រះអាទិត្យ ... ព្រះអាទិត្យស្អីទេ ... លោកយាយប្លែកពួកគ្មានអីចឹង ។

- ខ្ញុំក៏ឃើញហេលោកយាយនាងដូចកូនក្មេងដែរ ។ លោកតាទីងមិនហួសប្ដូចចង់អញ្ជើញពួកយើងទៅលេងឯកោះខ្យងទៀត ម្ដេចគាត់មិនព្រមទៅ, ហេតុអ្វីនាំនាងលោតទឹកសម្លាប់ខ្លួន? គិតទៅគាត់ចិត្តខ្លាំងណាស់ហ្ន៎ !

អាស៊ីវតបទាំងស្រងូត:

- រឿងនេះ, ខ្ញុំក៏មិនយល់ដែរ ប្រហែលជាមានអាថ៌កំបាំងអ្វីមួយក្នុងរឿងនេះមិនខាន ...

នាងក្រមុំដកដង្ហើមវែង ហាក់ចង់បន្ធូរនូវអារម្មណ៍ស្មុគស្មាញនានា ពីក្នុងខួរក្បាល ... នាងពោលបន្ត:

- រឿងលោកយាយនិងលោកតាទីងមិនប្ដូសប្ដូនមានការទាក់ទងគ្នាយ៉ាងណាៗនោះ ខ្ញុំជាក្មេងសារព្រោយ មិនអាចដឹងដល់ទេ ហើយលោកយាយក៏មិនដែលនិយាយប្រាប់ខ្ញុំដែរ ខ្ញុំគ្រាន់តែដឹងថា លោកយាយហាក់ដូចជាស្អប់តាចាស់ត្រកូលទីងខ្លាំងណាស់ ... ពោលតែប៉ុណ្ណោះនាងងាកមកសួរមាណព:

- ខ្ញុំមានសំណូមពរមួយមិនដឹងបងព្រមឬមិនព្រម ... នាងបង្អង់បន្តិចទើបបន្ត: គឺថានៅរាល់ពេលប្រយុទ្ធ ឲ្យតែដល់ពេលពិបាកបងត្រូវប្រើស្នៀត "ស៊ុំស្ពុំ ស្ពាបឆ្វេង" នេះជានិច្ចណា! ...

សំណើអាស៊ីវនេះ ស្របនឹងគំនិតនាយទាំងស្រុង ហេតុនេះគ្រាន់តែនាងពោលចប់ នាយងក់ក្បាលទទួលភ្លាម ធ្វើឲ្យអាស៊ីវអរ រឹបរខុប ប្រញាប់ប្រញាល់លុតជង្គង់ចុះសំពះនាយផ្ដោមៗ ....

ស៊ីងតានទីងមាំង ប្រញាប់ឃាត់:

– ហេតុអីអ្នកនាងធ្វើអ៊ីចេះ ?

អាស៊ីសំពះហើយសំពះទៀត បណ្ដាលឲ្យស៊ីផានទៀនក្ដួលមិនដឹងគិតយ៉ាងណាក៏លុតជង្គង់សំពះតាន់ៗញញាបស្អែក, ខណៈគេក្រាបតែពុតមេឃនារីម្នាក់ហ្នឹងនាយដោយត្រេកត្រអាលស្ទើរ...

– ហ៊ឺ ! មិនចេះខ្មាសគេទេ, ម៉េចក៏មកសំពះឲ្យសំពះអីចឹងគេទៀតហ្នឹង ?

ស៊ីផានមកពោះតឹបៗ ស្ដាប់ជាក់ជាសម្ដីនាងទីនតុន ។ នាយស្រែកឲ្យស្ទះក្រោកស្រែកខ្លាំងៗ .

– ទីនៗ តុនៗ ... ទីន... តុន..

នុះន៎ ! ទីនៗ តុនៗ គេចេញពីព្រៃមកដោយមានទីនមិនហួសពីនៅពីក្រោយ ។ ស៊ីផានភ័យព្រលឹងចុងសក់ខ្ទុនខ្ទប អាស៊ីរត់គេចជាបន្ទាន់ ។ ទីនមិនហួសពីលោតផ្លោះៗ រហ័សដូចកំប្រុកមកឈរពាំងមុខអ្នកម្នោះភ្លាម ។ មាណពស្រែកយ៉ូយ ! ម្ដងទៀតគេចផ្លូវទៅម្ខាង, តែដោយនាយមិនចេះសំកាលខ្លួនណាទើសនឹងអាស៊ីផង ទើបមិនយូរប៉ុន្មានតាទីនមិនហួសពីតាមទាន់ភ្លាម ទីនតុនឈរពាំងផ្លូវញញឹមញញែមនៅអាស៊ី ... ហើយញញាក់ការកាំបិតមួយក្ដៅក្ដែ នាយរឹតតែភ័យស្លន់ស្លោ ។

នាយភ្លេចឆ្ងាដូចមាន់រកពារ ទៅមុខមិនរួច ថយក្រោយក៏មិនរួច ។

ក្នុងពេលអាសន្ននេះ ស៊ីផានមិនទាន់ដឹងជាតាំងចិត្តយ៉ាងណាផង ស្រាប់តែអាស៊ីទាញត្រចៀកនាយខ្សឹបដាក់ :

– ម៉េចក៏បងមិនសំកាលខ្លួនលោតឡើងចុងឈើទៅគេចទៅ !

មាណពទីទើមិនដឹងត្រូវធ្វើយ៉ាងណា ... អាស៊ីយល់ថានាយមិនចេះស្ទៀតសំកាលខ្លួនក៏ប្រាប់:

– បងត្រូវស្រូបខ្យល់ចូលឲ្យពេញសួត សំរួលដង្ហើម បញ្ចេញកម្លាំងធាតុចុះទៅចុងជើង ហើយយោគយាកឡើងទៅលើ ។

ស៊ីផានធ្វើតាមធ្វើតាម តែដោយនាយមិនទាន់បានហ្វឹកហ្វឺនឲ្យបានប្រាកដ ណាមួយខ្លួនជាប់ស្ពាយអាស៊ីផង ធ្វើឲ្យទម្ងន់ខ្លួននាយធ្លាក់ចុះពេញទំហឹង ជាហេតុឲ្យញរ័រញ្ជួយ តែមកហ្ហូតដល់ត្រួយដើមទាំងមូល រកកល់នឹងបាក់ ។

អាស៊ីនឹករស់សំណើច :

– បងកុំបណ្ដោយឲ្យទម្ងន់ខ្លួនធ្លាក់ចុះតាមអំពើចិត្តដូច្នេះ ត្រូវសំកាលទម្ងន់ខ្លួនឲ្យស្រាល

Khmer Story Lovers



ផាំងនេះ ...

ពេលមិនទាន់ចប់ ស៊ីផនតាន់ធ្លាក់លើមែកឈើមួយទៀតត្រូវ ។ មួយនេះនាយប្រញាប់ធ្វើតាមកាស៊ីរ ដោយកក្តិញដើម្បីទុកបាំងបង្អួច ។ ក្លាយនោះមែកឈើគ្រាន់តែគាំង ទន្ទិចតែកពិតមែក តែតកបាក់ដូចមុនទេ ។ មាណពបំផ្លាញកាយបានខ្ពស់ទៀត ពួកតែសម្រេកទីនតុនជេះមិនឈប់ឈរល្ហើយ ។ ... ស៊ីផនាន លោតពីមែកមួយទៅមែកមួយដូចវាសប្បាយណាស់, អាស៊ីរនៅក្នុងរន្ធនៃដៃនាយក្រោប គឺបង្គាប់ឲ្យពេះរបៀបបញ្ចូកហុំងសំពលខ្លួន ហក់ហោតលើចុងឈើបានតាមចិត្តដូចសត្វស្វាប្តូរសំពោច ។ នាយបានជួបការសប្បាយកែកាយថ្មី ដែលមិនធ្លាប់ប្រទះកំពោល :

– មធ្យោបាយនេះប្រសើរពេកាស់, តែប៉ុណ្ណេះល្មមត្រូវដេញតាមសម្ងាប់យើងសែមបានហើយ ។

នាយនុមអាស៊ីរហក់ពេកពីតផុតព្រៃស្រាប់តែឮសម្រែកឡូឡាទៅខាងនាយ ហើយឃើញពន្លឺងាទិចាំងថ្ងៃផ្លេកៗ ជាសញ្ញាប្រយុទ្ធគ្នា ។ មាណពឃើញមនុស្សច្រើននាក់កំពុងប្រយុទ្ធគ្នា--

– ទីររហើយ, ខាងមុខមានមនុស្សផង, យើងចុះទៅមើល មើល៍ !

នាយដាន់មែកឈើមួយ លោតទៅមែកឈើមួយដោយប៉ិនប្រសប់ កុំថាឡើយខ្លួនទទេ ទោះឱបមនុស្សម្នាក់ផង ក៏នាយនៅតែទម្លាក់ខ្លួនបានស្រួលក្នុងគុម្ពោតព្រៃមួយ ។ ស៊ីផនានងើតក្បាលលបមើលទៅ នាយភ្ញាក់ក្រញាងបិះភ្លត់មាត់ស្រែក ព្រោះឃើញជនពីរនាក់ប្រយុទ្ធគ្នាយ៉ាងស្វិតស្វាញ ។ ម្នាក់ជាប៉ាយវ៉ាន់ដាន ខាងក្រុមភ្នំទឹកកក ម្នាក់ទៀតជាទីងមិនបាសង់ដៃទទេ, នៅជុំវិញគឺសស្រុកកកកឈររកាន់ដាវតង្វឹជុំវិញ មើលនាគប្រយុទ្ធយ៉ាងអន្ទះអន្ទែង ។

ទីងមិនហួសប្អូនឥតអាវុធមែន តែដៃទាំងពីរបញ្ចេញស្នៀតវាយលុក ប៉ាយវ៉ាន់ដាន យ៉ាងសាហាវដូចមានកន្ទុះផ្លែរ, ត្រូវតែប៉ះផ្លែដាវមុខជាកំបុតដៃមិនខាន ។

ស៊ីផនានឈរពិនិត្យមើលក្មេចខ្លួនថា នាយកំពុងរត់គេចពីសត្រូវ ។ មាណពាកំពុងតែសង្កេតលើនាគប្រយុទ្ធ, មើលស្នៀតភ្នំទឹកកកដែលប៉ាយ វ៉ាន់ដាងសម្ដែង ឃើញខុសពីស្នៀតភ្នំទឹកកកដែលនាយធ្លាប់ហាត់ជាងពាក់កណ្ដាល ។ មើលយូរៗទៅ រឹតតែធ្វើឲ្យនាយចង់ចេះ ចង់ស្គាល់យុទ្ធសិល្បៈបន្តិចម្ដងៗ ។

ទីងមិនហួសប្អូនវាយសុកខ្លាំងឡើងៗ ដោយចង់បានជ័យជំនះ ក្នុងពេលឆាប់ៗនេះ

ដែរ បន្តិចឲ្យប៉ាយវ៉ាន់ដានលើកដាវវិញ , តែប៉ាយវ៉ាន់ដានចំអត់ធ្មត់ទប់ទល់យ៉ាងស្វាត់ស្វៀមស្ងាត់ ។ មើលមួយភ្លែតគេអាចយល់ច្រឡំថា ទឹងមិនហួសប្អូនបានប្រៀបជាង តែការពិតវាយយូរទៅទៀតប៉ាយវ៉ាន់ដានអាចឈ្នះវិញផងក៏មិនដឹង ។ ស៊ុំផានឈរមើលយល់ចំណុចត្រង់នេះណាស់ , ចំណែកគូប្រយុទ្ធទាំងពីរនាក់តែយល់ច្បាស់ដែរ ព្រោះទឹងមិនហួសប្អូនតែងរំពឹងអាងថា គាត់បានពិភពយុទ្ធសិល្បៈស៊ើលោកគ្រូធំចាយត្រូវកំទឹកកកដាក់ពុកប៉ាយវ៉ាន់ដាន ម្ល៉ោះហើយគាត់មិនខំប្រើការគុនទេ ខ្លាចគេចោទថា ចាស់ធ្វើបាបក្មេង ។

គាត់គាំងចិត្តថាក្នុងរវាងចិតសិបពីរស្ទៀត គាត់អាចដណ្តើមដាវប៉ាយវ៉ាន់ដានបាន ។ ប៉ុន្តែកាលបើបានចូលប្រឡូកភ្លាមគាត់ក៏យល់ច្បាស់ ព្រោះគាត់ស្មានខុសថា ប៉ាយវ៉ាន់ដានមិនពូកែលើសសិស្សភ្នំទឹកកកឯទៀត ដែលគាត់ធ្លាប់ប្រយុទ្ធឡើយ ។ តម្រូវឃើញច្បាស់ថាប៉ាយវ៉ាន់ដានមានថ្វីដៃពូកែលើសបងប្អូនរួមគ្រូច្រើនណាស់ អាចបាត់ទុកជាគ្រូបើញូកទាំងនោះផង ។ ប៉ាយវ៉ាន់ដានបញ្ចេញស្ទៀតប្រចាំក្រុមទាំងចិតសិបពីរស្ទៀត យ៉ាងរហ័សរហួនព្រមទាំងមានការប្រែប្រួលយ៉ាងប៉ិនប្រសប់ ព្រោះគាត់ធ្លាប់ទទួលការណែនាំពីនាយក្រុមកាលនៅពីក្មេងផង ។

ទឹងមិនហួសប្អូនវាយលុកមួយសន្ទុះ ក៏ស្រែងស្ទូវរហ័សរហួន ព្រោះព្រិលភ្លែកនឹងពន្លឺដាវប៉ាយវ៉ាន់ដាន បើបន្តទៅយូរគាត់ច្បាស់ជាបរាជ័យ គាត់ផ្ទុះញូកច្បាមដាវនិងគ្រឿង-បង្ខំឲ្យ ប៉ាយវ៉ាន់ដានដកដាវបោកថយក្រោយ ទប់ខ្លួនប្រុងយកស្ថានភាពប្រយុទ្ធជាថ្មី ។ ម្តងនេះគាត់វាយលុកម្តងសន្សំមួយៗ ហាក់មានសង្ឃឹមយ៉ាងមាំថានឹងវាយផ្តួលគូប្រយុទ្ធ ក្នុងរយៈពេលខ្លីបាន ។ បើនិយាយលើយុទ្ធសិល្បៈ សុទ្ធសាធទឹងមិនហួសប្អូន មិនស៊ីសងគ្នានឹងប៉ាយវ៉ាន់ដាន ប៉ុន្មានទេ ។ ប៉ុន្តែពេលនេះគាត់មានះកោកមិនព្រមដកអាវុធមកប្រើ ផ្ទុយទៅវិញ , ប៉ាយវ៉ាន់ដាន មិនដែលពាក្យទណាទៀយ ឲ្យតែគាត់បានដាវក្នុងដៃ ។

ស៊ុំផានតាមដានការប្រយុទ្ធឥតដាក់ភ្នែក ។ បន្ទាប់ពីសុំសរទ្ធបានមួយស្ទៀត , ប៉ាយវ៉ាន់ដាន បានប្រែស្ទៀតយ៉ាងរហ័ស កាប់រះជើងទឹងមិនហួសប្អូន ធ្វើឲ្យគាត់របូតមាត់សរសើរ:

— គុនដាវភ្នំទឹកកកគ្រាន់បើមែន !

ប៉ាយវ៉ាន់ដានគ្រហឹម ហឺះ! ចុងច្រមុះមិនចេញស្តី ។ ទឹងមិនហួសប្អូនបន្ត:

— កុំអាលក្អេងក្អាងពេក ! ហឺះ! បើគ្រាន់បើណាស់ ភ្លក់មួយស្ទៀតនេះលមើល ?

និយាយចប់គ្រវីដៃទះឆ្វេង ទះស្ដាំយ៉ាងរហ័ស ឃើញដូចគាត់ឈរនៅកណ្តាលរង្វង់ ។ ស្ទៀតនេះ

ចំឡែកណាស់ ធ្វើឲ្យប៉ាយវ៉ាន់ដានថយក្រោយ , ទីនមិនហួសប្អូនសើចហាស ៗ ទន្ទ្រាំជើងស្ដាំ លោតទៅឆ្វេងផ្ទាត់ពោលពាក្យកាយគាត់ពុតពី ៗ ប៉ាយវ៉ាន់ដានដែលឈរក្បែរនោះកាន់ដាវនៅចាំ ក គ្រវាត់ការពារផ្នែកខាងមុខ ៗ ទីនមិនហួសប្អូនឥតរើរលំទេ, កេតផុតដីកាលណា ក៏ទេវខ្លួន ពេញអាកាស បណ្ដាលឲ្យស៊ីផាងដែលក្លួចមើលពីចម្ងាយព្រិលភ្នែក ៗ ស្រាប់តែឮ ខ្វាក! ផ្លែដាវប៉ាយវ៉ាន់ដានកាប់ជើងខោទីនមិនហួសប្អូនដាច់មួយផ្ទុក ៗ ទោះមិនដាច់សាច់របក់ស្បែក ក៏អាចចាត់ថា តាចាស់ចាញ់ប្រៀបគេដែរ ៗ

ប៉ាយវ៉ាន់ដានដកដាវថយក្រោយពោល :

- អរគុណហើយ ! ការប្រយុទ្ធរវាងអ្នកក្លាហានដូចគ្នា សន្មតថាចប់ត្រឹមណោះចុះ

ទីនមិនហួសប្អូនឆ្លួលចុនច្រមុះ មិនព្រមឈប់ទេ, គាត់គំហក :

- អ្នកណាឲ្យឯងអរគុណយើង ? មួយស្នៀតនេះគឺឯងមានសំណាងល្អ មិនត្រូវចាត់ទុកថា យើងចាញ់ទេ ៗ

ពោលចប់គាត់សំដែងស្នៀត "រូសទូកបញ្ច្រាសទឹក" វាយលុកប៉ាយវ៉ាន់ដានសារជាថ្មី ដោយគាត់ យល់ថា អម្បាញ់មិញជាសំណាងមែន , ព្រោះពេលតាចាស់លោតឡើងលើ ព្រមពេលប៉ាយវ៉ាន់ដានយារដាវកាប់ហាក់ដូចតាចាស់រុញជើងខោជូនអ្នកក្លាហានទិសឧត្តរកាប់ដាច់ដូច្នេះដែរ ៗ តាចាស់វាយបុកមួយស្នៀតមកទៀត, ប៉ាយវ៉ាន់ដានលើកដាវរាំង និងចាក់សងវិញយ៉ាងរហ័ស ធ្វើឲ្យគាត់លោះព្រលឹង រឹតតែប្រុងប្រយ័ត្នជាងមុន ៗ

ពេលនេះតាចាស់ចាញ់ប្រៀបប៉ាយវ៉ាន់ដានមួយគំរិត ម្នីម្នាផ្ចង់ស្មារតីសម្លឹងប៉ាយ វ៉ាន់ដានឥតព្រិចៗ សិស្សភ្នំទឹកកកដែលឈរព័ទ្ធជុំវិញលាន់មាត់សរសើរ :

- គនយើងមើលស្នៀត " ពន្លឺអាប់អួ " របស់ក្រុមយើងវិសេសវិសាលណាស់ អ្នកស្មមៗ មើលមិនយល់ច្បាស់មែន ! នេះបានហៅថាបុរសល់នៃគុនដាវប្រចាំក្រុមភ្នំទឹកកក មែន ៗ លោកគ្រូទីនមិនហួសប្អូនរលះរលាំងគ្រាន់បើ កុំតែលោកបង់សន្ដោស ម្ល៉េះសមត្រូវកំបុតជើង ហើយ !

ទីនមិនហួសប្អូនមិនទាន់ឆ្លើយផង ស្រាប់តែឮសម្លេងមួយទៀតលាន់ពីចម្ងាយថា :

- និយាយផ្ដាស !

សម្លេងនេះលាន់ពីទិសខាងកើតដែលគ្មាននរណានៅ ។ គេក្រឡេកមើលម្ចាស់សម្លេងគ្រប់គ្នា ស៊ីផានក៏មើលទំនងដែរ ហើយនាយក្លាក់ផ្អើលភ័យជាងនេះថែមទៀត ព្រោះនាយឃើញមនុស្សពីរនាក់ឈរទន្ទឹមគ្នាក្រោមដើមឈើ ព្រោះជាទីងមិនហួសបី ព្រមទាំងទៅស្រីទីង ១ តួន ១ ដែលនាយញញើតនោះឯង ។ ទីងមិនហួសប្អូនឃើញបងស្អូនមកដល់ទៀតស្រែក:

– លោកបងទីងបី ឆាប់ចៀសចេញឲ្យឆ្ងាយខ្ញុំកំពុងតែប្រយុទ្ធនឹងគេ, លោកបងមកធ្វើអីដែរ ?

ពីរនាក់បងប្អូននេះមិនដែលឃើញមុខគ្នាសោះ ស្គាល់សំឡេងគ្នាដែរ ។ ទីងមិនហួសបីសើចហាស ៗ

– ចេញគ្នាទៅណាហ្នឹង ? បងចង់មើលស្នាដៃប្អូនម្ដងណា ! ចុំគ្មានឆ្នាំទេប្អូនជឿនជឿនដល់កំរិតណាដែរ ?

ទីងមិនហួសប្អូនអន្ទះអន្ទែងណាស់ដឹងច្បាស់ថានាគប្រយុទ្ធនេះ ត្រូវបញ្ចប់ដោយបរាជ័យរបស់គាត់ហើយ ៗ ចង្រៃពេជន្សអីបងទីងមកឃើញផ្ចាលៃក្លួនទៀត ? គាត់ទីងណាស់ស្រែកខ្លាំងៗ:

– លោកបងផ្ញើដំណើរមកទីនេះធ្វើអ្វី នាំតែអាប្អូកខ្ញុំបែកក្លួកបែកអ៊ីចង់ណាយប្រទូកជាមួយគេទេ ៗ

ទីងមិនហួសបី ពោលចំអក:

– បងក្រែងប្អូនទីប្អូនឯងដាច់ ជើងខោ ម្ដងទៀតណា៎ !

ទីងមិនហួសប្អូន ស្រែកបន្ទប់ :

– អាក្រកូលបាយនេះចេះគុនដាវប៉ុណ្ណឹង វានឹកស្មានថានណាពូកែជាងគេ , ដូចជាខ្លួនគ្នាក្លាងក្លាងណាស់ ៗ បន្តិចទៀតលោកបងទីបីឯង បើកភ្នែកធំ ១ មើលឲ្យច្បាស់មើល? ពីតាទីប្អូននេះនឹងប្រើតែដៃទទេ វាយវាឲ្យជ្រុះ ដាវពីដៃទម្លាក់ចុះចាញ់ ហើយលុតជង្គង់សុំទោសសុំទុកជីវិត ៗ ទីងមិនហួសបី អស់សំណើច សើចខ្លាំងៗ: ហាស់ ... ហាស់

សំណើចគាត់លាន់ខ្ទរពេញអាកាសប្រសៀកត្រចៀកពិបាកស្ដាប់ណាស់ ។ ទីងមិនហួសប្អូនទៀតសន្ទាប់:

– លោកបងទីបីសើចខ្ចោចអី ?

– បងសើចប្អូនឯងហ្នឹងណា៎ !

Khmer Story Lovers



- សើចខ្ញុំធ្វើអី ? ខ្ញុំមានរឿងណាគួរឲ្យសើច ?

-បងសើចថាមួយជាតិនេះប្អូនឯងចេះតែចង់ឈ្នះគេរហូត ។ ពេលនេះដល់អាសន្នមកដល់ហើយប្អូនឯងត្រូវពឹងផ្អែកបងជាដាច់ខាតណា !

ទីងមិនហួសប្អូនមុខក្រហម, ស្រែកសន្ធាប់ទៀត:

- អាត្រកូលប៉ាយនេះជាសិស្សជំនាន់ក្រោយទេ បើខ្ញុំមិនយោគយល់ឪពុកម្ដាយវា ម្ល៉េះខ្ញុំសម្លេះវាបាត់ទៅហើយ ។ គ្មានអាសន្នទេ លោកបងកុំបាច់ជួយ កុំបាច់ព្រួយ ទៅរកស្រាមកក្លែមម្នាក់ឯងចុះ ។ យើ ! អាចង្រៃឆ្លៀតពេលដែលយើង...

ត្បិតគាត់រវល់ប្រយុទ្ធឯណោះទៅឆ្លៀតនិយាយសាសងជាមួយទីងមិនហួសបី ទើបប៉ាយវ៉ាន់ដានឃើញចន្លោះល្អ វ៉ាត់មួយដាវត្រូវស្មាឆ្វេងគាត់បាញ់ឈាមច្រាវក្រហមច្រាល ។ បងប្អូនទីងទាំងពីរធ្លាប់ឈ្លោះប្រកែកគ្នាតាំងពីដើមមក, ប៉ុន្តែពេលនេះឃើញទីងមិនហួសប្អូនរបួស ទីងមិនហួសបីទឹងក្រោធណាស់ស្រែក :

- អាច្រមក់ឯងហ៊ានវាយប្អូនយើងឲ្យរបួសផងឬ ?

ពោលចប់កន្ត្រាញជើងស្ទុះរូទៅចាប់ខ្លួនប៉ាយវ៉ាន់ដាន ៗ ដឹងថាសត្រូវវាយលុកពីក្រោយខ្នងមែន, តែគាត់ឥតភ័យទេ គ្រាន់តែគ្រវាសដាវចាក់ទីងមិនហួសប្អូនបង្ខំឲ្យគាត់ថយសិនទើបបង្វិលខ្លួនមកទប់ទល់និងទីងមិនហួសបីតាមក្រោយ ៗ ទីងមិនហួសប្អូនមានះណាស់ :

-លោកបងទីបីថយចេញឆាប់ឡើង, គ្មាននរណាហៅបងមកជួយទេ ។

- អ្នកណាថាបងជួយឯង ? យើងឃើញឆាកប្រយុទ្ធដែលមិនយុត្តិធម៌យើងទើសភ្នែកណាស់ តើបានជាចូលមកវាយផ្ទៃដាវមួយនេះបំបាក់ចោលឲ្យម្ចាស់វារបួសចេញឈាមសិន ។ រួចពីនោះឯងប្រយុទ្ធគ្នាទៀតទៅ !

សិស្សភ្នំទឹកកកឃើញ បងប្អូនទីងប្រួតគ្នាវាយបង់ខ្លួនដូច្នេះក៏ស្រែកឡូឡាស្ទុះចូលព្រួ ។ អ្នកអស់នេះស្អប់ទីងមិនហួសបីដែលសម្លាប់បងប្អូនគេពីរនាក់មុនដងទើបវាយសម្រុក ឥតសំចៃដៃតែទីងមិនហួសបីស្រែកសន្ធាប់ :

- ពួកឯងធុញទ្រាន់នឹងការរស់នៅហើយឬ ? ចៀសចេញឲ្យឆ្ងាយវ៉ឹយ !

ខណៈនោះឃើញពន្លឺដាវផ្លេក ៗ ក្នុងអាកាសគឺទីងមិនហួសបីវាយសិស្សភ្នំទឹកកកខ្ទាតដាវអស់ខ្លះ

ហើយស្រែកទៀតៈ

– បើមិនចៀសចេញប្រយ័ត្នយើងសម្លាប់ណា !

ប៉ាយភាន់ជានដឹងច្បាស់ថាប្អូនតាំងអស់មិនឈ្នះគេទើបស្រែកឃាត់ៈ

– ប្អូនរាល់គ្នាថយក្រោយវិញភ្លាម ៗ

សិស្សភ្នំទឹកកកនោះពបញ្ឈប់ជើងដកខ្លួនថយជាបន្តបន្ទាប់គ្នា ។ ទីងមិនហួសបីចង្អុលសិស្សភ្នំទឹកកកម្នាក់ដែលមានមាឌមាំៗតាបឈ្មោះ លីភាន់សានពោលថាៈ

ហុចដាវឯងមកឲ្យយើង !

លីភាន់សានទឹងក្រវែស្រែកតបៈ

– ហក៏យកទៅចុះ !

ពោលផង អន្ទ្រូនដាវចាក់សំដៅក្បាលពោះទីងមិនហួសបីផង ។ នាងចាស់ល្មួកដៃឆ្វេងចាប់កដៃនាយជាប់កញ្ជ្រក់ដាវបានដូចបំណងមិនខុសពីលីភាន់សានប្រគល់អាវុធឲ្យគាត់ ដោយស្រួលឡើយ តែនាយភ្លាត់ផ្គើងឈើបែកញើសជោក ។ ទីងមិនហួសបីឆ្លៀតទាត់នាយដាំដួងមួយក្រឡប់ទៀតធ្វើឲ្យសិស្សភ្នំទឹកកកខឹងញ័រទ្រូងប្រុងស្ទុះចូលជួយ ។ ភ្លាមនោះទីងមិនហួសបីគូសរង្វង់មួយយ៉ាងធំជុំវិញប៉ាយភាន់ជាននិងប្អូនគាត់ហើយឈរប្រកាសប្រាប់សិស្សភ្នំទឹកកកៈ

ឲ្យតែនរណាម្នាក់ហ៊ានចូលក្នុងរង្វង់នេះមួយជំហ៊ានអ្នកនោះ ដូចជាចូលទៅជាន់ឋាននរកអីចឹង !

ប៉ាយភាន់ជានមានទឹកមុខនឹងនតែចិត្តអន្ទះអន្ទែងបារម្ភណាស់ ដោយដឹងថាបងប្អូនត្រកូលទីង ជាជនកំណាចសម្លាប់មនុស្សឥតញញើតដៃ ។ ពេលនេះគេរួមគ្នាផងច្បាស់ជាមិនឈ្នះទេ ។ ឆាកប្រយុទ្ធម្តងនេះ មានភាពសាហាវប្រកបដោយគ្រោះថ្នាក់ ជាងកាលគាត់ប្រយុទ្ធជាមួយម្ចាស់ភូមិសាំងស៊ីនៅក្នុងរោងកញ្ចាស់ទៅទៀត, ក្រែងប្អូនរួមគ្រូទាំងដប់ពីរនាក់ ស្លាប់បាត់បង់ជីវិតលើកោះផ្សែងខ្មៅនេះអស់ទេដឹង ?

ប៉ាយភាន់ជានកាន់ដាវបញ្ចេញសុទ្ធតែស្នៀតល្អប្រណីត ៗ និង កាចសាហាវប្រាថ្នាសម្លាប់ទីងមិនហួសប្អូនមុន , តែតាចាស់មិនមែនអន់ខ្សោយឡើយ ត្រូវប្ញូសប៉ុណ្ណឹងហើយ ក៏នៅរហ័សរហួនដូចធម្មតា ។ ចំណែកអ្នកក្លាហានទិសនត្ថរបង់ឈ្មោះភ្លាមៗ ទៅជាអន្ទះអន្ទែងសំដែងស្នៀត

មិនត្រឹមត្រូវសោះ ។ ទីងមិនហួសប្អូនត្រីវៃជាំងទ្វេលុកតាមចន្លោះផ្ទៃដាវតុកខ្ទីរលំនឹងឈាមហូរ រហាមតាមសាទៀយ ។ ទីងមិនហួសបីកាន់ដាវចូលមកជិតស្រែកប្រាប់ :

– លោកប្អូនទីប្អូនថយក្រោយរុំរបួសសិនចុះ ។

ទីងមិនហួសប្អូនមានអស្ចារ្យស្រែកប្រឆាំង :

– មុខរបួសស្អី ? ខ្ញុំមានរបួសត្រង់ណា ? ដាវកំប្លាក់របស់អាក្មេងនេះអាចធ្វើឲ្យខ្ញុំរបួសឬ?

ទីងមិនហួសបីសើចហាសៗ យារដាវតាក់ប៉ាយភាន់ដានវិញ ហើយស្រែកបន្ត:

–នែជនត្រកូលប៉ាយ ! ស្តាប់យើងឲ្យបានណា ! ពេលនេះយើងមិនមែនប្រកួតដៃវាយឯងម្នាក់ទេ ។ យើងវាយឯងព្រោះទីងមិនហួសប្អូនឃាត់យើង, យើងមិនស្តាប់, ឯទីងមិនហួសប្អូនវាយឯង ព្រោះយើងដេញវាចេញវាមិនព្រមចេញ ។ យើងមើលឯងប្រយុទ្ធគ្នាបែបនេះយើងពាស់ក្នុងណាស់ព្រាំមិនចុះទេ, ត្រូវប្រដៅឯងមុនឲ្យស្គាល់ជ្រាំខ្លាំង ។ ចំណែកប្អូនយើងក៏ស្អប់ខ្ពើមឯងណាស់ដែរ, វាចង់ទះកំផ្លៀងឯងឲ្យក្តីស្មានស្មារតី ។ យើងវាយគ្នាដោយមានដើមហេតុកុំសង្កាទេណា ពិ៍រលោថ្ងៃក្រោយឯងទោទថាអ្នកក្លាហានត្រកូលទីងតាំងបង្អូនប្រកួតធ្វើបាបក្មេងវ៉ុយ !

ទីងមិនហួសបី និយាយបាំង ៗ ឯដៃតាក់មិនទំនេរទេ បញ្ចេញសុទ្ធតែស្នៀតកាចសាហាវជាទីបំផុត ។ ប៉ាយភាន់ដានទំទប់ទល់បណ្តើរនឹកគួចចិត្តបណ្តើរ :

– ឯងជាម្នាក់ ៗ វាយយើងដោយដើមហេតុខុសគ្នាមែន, តែនេះមិនតឹងឯងប្រកួតគ្នាពីរនាក់ទល់នឹងម្នាក់ឬ ?

ប៉ាយភាន់ដាន ជាមនុស្សស្លូតត្រៀមមិនសូវចូលចិត្តដៃគងង ស្អប់ខ្ពើមពួកពាលអាងចាសត្រកូលទីងតាំងពីដើម ជាពិសេសតាក់កាត់វង់ដោយលំបាក ក៏ចេះតែទំទប់ទល់ដោយគតធ្វើដឹងព្យួរឡើយ

គេកេះតែបញ្ចេញស្នៀតមុឺនមួយ ៦ ស្រាប់តែទីងមិនហួសបីយារដៃចាប់ដាវប៉ាយភាន់ដាន ព្រួចឹង ៖ ភាន់ដានញ៉ាំដៃដកទ័យមួយជំហានត្រឡប់វិញមួយជុំខ្វាល់ តែជើងស្តាំគាត់បែរជាជុកចាប់យ៉ាងខ្លាំង ដោយតាទីងមិនហួសប្អូនទះមួយដៃយ៉ាងពេញ ។ ប៉ាយភាន់ដានស្រែកព្រោតតរកកល់ដួល សិស្សភ្នំចិកកកស្រែកគ្រវ :

– គុំវាយបងប្រុយើងទេរួសណា!...

គៅស្រែកហើយស្ទុះចូលវាំងប្រាថ្នាជួយ ប៉ាយភាន់ដាន គ្រាន់តែឈានជើងទ្វេនកុតរនូនមួលភ្លាម

ពន្លឺដាវចាំងភ្លែត ! ទីងមិនហួសបីចាក់ទម្លាយទ្រូងសិស្សម្នាក់ស្លាប់មួយរំពេច ។ សិស្សពីរនាក់ភ័យផងខឹងផង ស្ទុះចូលវិញ ! ទីងមិនហួសបីស្រែកសន្ធាប់ខ្ញ័រញៀវ លោតផុតយារដាវកាប់ពីលើមកផង យារដៃម្ខាងទទះថែមផង ។ ផ្លែដាវបានពុះច្រៀកខ្លួនសិស្សភ្នំទឹកកកម្នាក់តាំងពីស្មារហូតដល់ជើង, ឯដៃម្ខាងទទះត្រូវក្បាលសិស្សម្នាក់ទៀតព្រួស ! ដួលគ្រេងបាក់កទន់ល្វៀក ។ ក្នុងមួយប៉ប្រិចភ្នែក ទីងមិនហួសបីប្រហារជីវិតសិស្សភ្នំទឹកកកពីររូបស្លាប់យ៉ាងអាណោចអាធ័ម ធ្វើឲ្យស៊ីផធានដែលលួចមើលក្រោយគល់ឈើ ភ័យស៊ីតស្ងាំងបុកពោះភឺប ៗ ។

ទីងមិនហួសបីនៅមិនអស់ចិត្ត យារដាវវាយលុកប៉ាយវ៉ាន់ផានដូចព្យុះសង្ឃរា ឮសូរក្រាក ៗ ផស ! ដាវទាំងពីរបាក់ដំណាលគ្នា, ហើយគូប្រយុទ្ធទាំងសងខាងត្រភ្លត់ចុងដាវតម្រង់គ្នាទៅវិញទៅមក រួចឱនក្បាលគោចដូចគ្នាទៀតគួរឲ្យល្អមើលណាស់ ទោះគេស្ថិតនៅជិតគ្រោះមរណៈក៏ដោយ ។ ប៉ាយវ៉ាន់ផានឈឺជើងម្ខាងហាក់លោតមិនសូវស្រួល ហើយអស់អាវុធទៀត គឺធ្លាក់ក្នុងសភាពទុនដាបភ្លាំងទៀនឹងគ្មានឱកាសវាយតបវិញសោះ ។

សិស្សភ្នំទឹកកកពីរនាក់ ទោះដឹងថាចូលក្នុងវង្វង់មូលគ្មានផ្លូវរស់រានមានជីវិត ក៏គេមិនអាចព្រងើយកន្តើយ ឲ្យតាចាស់ទីងចង្រៃរួមគ្នាវាយប្រហារបងប្រុសគ្រូគេដែរ ម្ល៉ោះហើយគេគាត់ដាវស្ទុះចូលទៅភ្លាម ។ ទីងមិនហួសបីស្រែក :

— ប្អូនទីបួនចាត់ការចុះ ! ថ្ងៃនេះបងសម្លាប់បីនាក់ហើយ !

ទីងមិនហួសប្អូនសើចហាស ៗ :

— ឯងចេះអន្ទូរហៅរកឈើងដែរឬ ?

គាត់មិនបាច់ងាកមើលផងទេ , លើកជើងទាំងពីរធាក់ដូចសេះព្យុះប្រុសគ្រាំង ! គឺគាត់ធាក់ត្រូវសិស្សភ្នំទឹកកកទាំងពីរចំកណ្ដាលទ្រូងខ្ទាតទៅក្រោយដួលគ្រេងស្លាប់ដោយឥតបានស្រែកមួយម៉ឺះទេ ។ បងប្អូនត្រកូលទីងកាចសាហាវផុតលោកិយ ឥតរវល់នឹកនាដល់ច្បាប់ពិភពគុនឬមនុស្សធម៌អ្វីឡើយរួមគ្នាសំដែងស្នាដៃតែស្នៀតកំណាចវាយលុកប៉ាយវ៉ាន់ផានថ្លុន ៗ ។ អ្នកក្លាហានរូបនេះឈឺជើងម្ខាងលើកលែងរួច ហើយចេះតែថយក្រោយ បន្តិចម្ដង ៗ លុះគ្រាជិតផុតវង្វង់មូល ។ ទីបំផុតគាត់ថ្ងូរហ៊ឹះ ដោយទីងមិនហួសប្អូនទះត្រូវមួយដៃ ស្ទើរលើកលែងរួច ។

ស៊ីផធានដែលលបគយគន់ឆាកប្រយុទ្ធដ៏អយុត្តិធម៌ , ទ្រាំលែងបាន ក៏ស្រែកឡើង:

- រឿងនេះមិនយុត្តិធម៌ទេ !

ហើយនាយខ្មៅម្នាក់ទៀតសុីវទៅដី ដកកាំបិតកញ្ចាស់ពីចង្កេះគោះជិតហានទៅមុខព្រមទាំងស្រែកខ្លាំង ៗ:

- ពីនាក់ប្រកួតគ្នាវាយម្នាក់ដូច្នេះមិនសមទេ ។

## ចម្លើក ២១

## ចិញ្ចៀនរាំមិត្តព្រះអាទិត្យ

អាសុីវត្រូវមាណពខ្មៅម្នាក់បោះបោកប្រាច់មុននាងស្រែកថ្ងូរ ! សុីផានងាកមកពោលថា: អត់ទោស !

ហើយនាយលោតផ្ទោះចូលក្បាលផ្ទុនមួយ ៗ ទីនមិនហួសប៉ូនឥតខ្ចីបែរក្រោយ, លើកជើងធាក់ទីងទៀតតែសុីផានចង្រ្កានជើងពេលគោះក្រោយស៊ើតិច្ឆេះទាំងក្បាលទីនមិនហួសប៉ូន ទៅឈរពីមុខគាត់វិញធ្វើឲ្យទីនមិនហួសប៉ូនភ្ញាក់ក្រញាង:

- យី ! អាអន្យមធំឯងទេ ឬ !

- បាទ, មែនហើយ ៗ លោកតាទាំងពីរ . . . ទាំងពីរវាយមនុស្សម្នាក់ដូច្នេះមិនយុត្តិធម៌ទេ ។

ពេលផាន់ងាកមើលមុខទីនមិនហួសប៉ូនទាំងភ័យក្តុកក្តាក់ផង ៗ ក្រឡេកឃើញសាកសពសិស្សក្តីងកកស្លាប់ពេលប្រឡូកឈាមស្រេកាក នាយកែកភ័យទ្វើតៀង ៗ ទីនមិនហួសប៉ូនស្រែកថា:

- អាអាប្រមក់ ! ឯងនៅព្រៃពីផុតពុកយើងមករស់ទីនេះហើយ, ម៉េចចេញមុខមកធ្វើអីទៀត ?

- ខ្ញុំចេញមកអង្វរលោកតាទាំងពីរកុំឲ្យធ្លួញបត្រូវព្រិចពេក, បើលោកតាឈ្នះហើយអាចបៀសវាងបានត្រូវសន្តោស ៗ កុំពេមសម្លាប់គេផុតក្បាលដូច្នេះ , ទីនមិនហួសប៉ូន និងទីនមិនហួសប៉ូនងាកមើលមុខគ្នាសើចហាយហាយ ៗ ម្នាក់បន្ទឹវាថា:

- លោកបងឯងបើរើយ ! អាប្រមក់នេះវាពោះពាក្យសត្វមកពីណាពោលផ្តេស ផ្តាសបែបនេះ, ហ៊ានប្រមាថយើងផង !

សុីផានកាន់កាំបិតក្តីះផាវមួយពោះឲ្យបាយផាន់ផាន ពោលថា :

– លោកគ្រូ, ក្រុមភ្នំទឹកកកត្រូវប្រើដាវ ។

ប៉ាយវ៉ាន់ផានពិបាកចិត្តណាស់ ។ អម្បាញ់មិញគាត់អស់សង្ឃឹមទៅហើយ រង់ចាំតែកញ្ចាស់ទីងទាំងពីរសម្រេះចោល, មិននឹកស្មានថា ស៊ីផុងយីសត្រូវផ្ទាល់ មកជួយធ្វើអន្តរាគមន៍សោះ ។ ឥឡូវគេគ្លឹះដាវមកប្រគល់ឲ្យហើយ ត្រូវទទួលដោយស្ងៀមស្ងាត់ជាជាងវៃទទេ ។ គាត់កាន់ដាវប្រុងស្មៀត, ទីងមិនហួសបីស្រែកជេរមាណព :

– អាត្រកូលប៉ាយចង់ចាប់ឯងយកទៅស្មោរ, បើកុំតែបានអញជួយ ម្ដេចឡើយឯងបានដកដង្ហើមរហូតដល់ថ្ងៃនេះអាល្អិត ?

ស៊ីផងានងក់ក្បាល :

លោកតាមានប្រសាសន៍ត្រូវណាស់, ព្រោះហេតុនេះហើយបានជាខ្ញុំសុំអង្វរលោកគ្រូប៉ាយផង បើអាចចៀសវាងត្រូវសន្តោស ។

ទីងមិនហួសបួនខ្លួច ស៊ីផងានបើកកកាយកឿង គាត់ប្រយុទ្ធចាញ់នាយលើទូកតូច គាត់ចង់សម្លាប់មាណពឲ្យផុតពីមុខឆាប់ ៗ ក៏ស្រែកថា :

– កុំស្ដាប់វានិយាយផ្ដេសផ្ដាសនោះ !

ចប់សំដីគាត់យារដៃទះតម្រង់ទៅ ។ មួងនេះគាត់ឥតញញើតទេ ព្រោះគ្មានយាយស៊ីនៅជិត ។ ស្មៀតនេះឈ្មោះ «ពពកខ្មៅមីរ» មិនដែលបង្ហាញមាណពទេ ។ ប៉ាយវ៉ាន់ផានមិនដាច់ចិត្តឲ្យនាយស្លាប់ភ្លាម, ក៏វាសដាវសំដៅស្មៀត រែកឈើខ្ទាត់ខ្ទេចចាក់ពីចំហៀង ។ ស៊ីផងានឃើញដូច្នេះនាយលើកកាំបិតកញ្ចាស់ប្រើស្មៀតព្រានព្រៃកាប់អុស កាប់ដៃទីងមិនហួសប្អូនដែរ ។ គួរចំឡែកណាស់ ! ស្មៀតដាវខាងក្រុមភ្នំទឹកកក និងស្មៀតគុនកាំបិតរបស់ក្រុមព្រះអាទិត្យ មានន័យផ្ទុយគ្នាស្រឡះ ។ លុះយកមកប្រើរួមគ្នាទៅជាមានឥទ្ធិពលខ្លាំងក្លាគ្របដណ្ដប់ទីងមិនហួសប្អូនជិតជុំរកប្រកចេញមិនរួច ។ ទីងមិនហួសបីរំពក :

– ប្រយ័ត្នខ្លួនលោកប្អូន !

គ្រាន់តែពោលដូច្នេះតែគាត់មិនហ៊ានចូលក្នុងវង្វង់ជួយប្អូនឡើយព្រោះពន្លឺដាវនិងកាំបិតកាចសាហាវហួសប្រមាណចាក់ស្រេះជាក្រឡាសំណាញ់ញឹកស្មើ ។

ទីងមិនហួសក៏ភ្ញាក់ផ្អើលជាខ្លាំង ដួលខ្លួនប្រមៀលចេញក្រៅគំនូសភ្លាម ។ លុះក្រោក

ឈរឡើងគាត់គ្រវីសក់ក្បាលដោយរបើញសរសៃពុកមាត់សរ ប៉ុន្តែគ្រប់ទិសយើងស្ទាបចន្លាទើបភ័យស្លោ ស្លូត ព្រោះដាវនិងកាំបិតកាប់រកចំអស់រលីងចោល ។

គាបាសត្រកូលទ័ងភ័យដូចគ្នា ,ទីនមិនហួសប្តូនទំនងថែមលើភ័យ , ឯប៉ាយកាំនជានស្ទូលជាខ្លាំង ៗ ហុនតែស៊ីផងានម្នាក់គត់ដែលដឹងច្បាស់ថា ស្មៀតគុនកាំបិតរបស់ក្រុមព្រះអាទិត្យពូកែអស្ចារ្យធ្វើឲ្យអ្នកក្លាហានដើរហាស់ចាំងបីរកោតស្ញប់ស្ញែងមែន !

បន្ទាប់មកទីនម៉ុនហួសបីកោលខ្លាំង ១ :

-មក ! ម្ហូប ! យើងប្រើអាវុធដូចគ្នាដែរ ។

គាត់ឧុនរើសដាវបាចឲ្យប្អូនមួយហើយស្រែកទៀន :

-គិតដល់ណាទៀត ? ចូលមក !

គាត់រលាស់ដាវចាក់សំដៅស៊ីផងានមុន ៗ ពានោពចំណាប់ប្រយុទ្ធឃើញគេវាយមកគិតមិនទាន់ទៅជាស្រឡាំងកាំង, ព្រោះល្អ បានប៉ាយរកនៅមាត់លោបដាវវាយប្រើស្មៀត ទាត់សេះចេញទៅឆាយក្រាក់ខ្លួនសំដែងស្មៀតបន្ត្រាបម៉ិតសេះ លើកកាំបិតសន្ទុះលើក្បាល ៗ កាំបិតនេះចាស់គំរិលមែនតែនាយបញ្ចូលកម្លាំងកាយមកម៉ាមួយធ្វើឲ្យទីនមិនហួសបភ័យបែកញើសថ្ងាសដែរ ទាល់តែទីនមិនហួសប្តូនហក់មកជួយទើបផុតគ្រោះថ្នាក់

បន្ទាប់ពីនោះប៉ាយកាំនរកនប្រើស្មៀតដាវខ្យល់បក់វាលខ្សាច់, ស៊ីផងានសំដែងស្មៀតកាំបិតឈ្មោះ « ខ្សាច់លិចបាតសមុទ្រ » តាមក្រោយ ។ កាលបើប្រើរួចគ្នាស្មៀតទាំងពីរនេះ មានសណ្ឋានដូចខ្យល់បក់ខ្សាច់ទាំងស្រទាប់ ១ នៅខាងលើ ឯខាងក្រោមពុសនុកខ្យល់ដូចទឹកសមុទ្រគ្រវីព្រះសមុទ្របោកបក់លេកទាំងពីរ ១ ខ្ទារត្រចៀក បងប្អូនត្រកូលទីនទាំងពីរភ័យស្រែកព្រមគ្នា ។

ស៊ីផងានមានកម្លាំងកាយសូត្រស្ទាក់ផ្ទាល់ យុទ្ធសាស្ត្រនេះចាំស្ទាត់អស់ហើយ ប្រើបានយ៉ាងរហ័ស និង ស្ទាត់ជំនាញ ចាស់តែម្នាក់ចាស់មុនចាប់ប្រយុទ្ធ មិនចេះបញ្ចេញស្មៀតការពារ ប្ដូរចំលះខ្លួនឯងសោះ ។ ស្មៀតគុនកាំបិតទាំងអស់ មានតែស្មៀតមុនក្រោយទីចិតសិបបីទេដែលប្លែក , ក្រៅពីនោះសុទ្ធតែជាគូចំនុះស្មៀតគុនដាវខាងភូមិកកក ។ ស៊ីផងានលែងព្រួយរឿងស្មៀតទប់ទល់ហើយ , នាយចាំមើលឲ្យតែប៉ាយកាំនបញ្ចេញស្មៀតណា .. នាយប្រើស្មៀត

គុនកាំបិតជាគូគ្នាវាភ្លាម ។

ព្រោះហេតុនេះហើយបានជាប៉ាយភាន់ជានប្រើស្នៀតមែកឈើខ្វាត់ខ្វែង នាយប្រើស្នៀតព្រានព្រៃកាប់គុស , ប៉ាយភាន់ជានប្រើស្នៀតទំពាសេះចេញទៅ នាយសំដែងស្នៀតបង្ក្រាបទំពាសេះ។

គ្មាននរណាដឹងថាគុនកាំបិតបង្កើតឡើងសម្រាប់បង្ក្រាបគុនដាវនៃក្រុមភ្នំទឹកកក , ហើយសំរាប់ប្រើរួមគ្នាបុកបញ្ចូលជាយុទ្ធសិល្បៈម្យ៉ាងពូកែចំណានរកស្មានមិនត្រូវឡើយ ។

ប៉ាយភាន់ជាននឿនធ្លស់ណាស់តែគាត់រក្សាចរិយាថ្លៃថ្នូរសក្តិសមជាអ្នកក្លាហាន មិនស្តីរមាណពមួយមាត់ឡើយគ្រាន់តែដឹងថាស្នៀតគុនទាំងពីររួមគ្នាមានឥទ្ធិពលខ្លាំងលើសលុបឥតនរណាបំបែកបាន ។ ជាពិសេសគាត់ធ្លាប់ត្រង់អាត្មចត្រកូលស៊ីនេះមានកម្លាំងកាយចំឡែកបញ្ចេញកាន់តែច្រើនរឹតតែខ្លាំងឡើង ។

បងប្អូនទំនងទាំងពីរនាក់មានការពិសោធន៍ច្រើនរឹតតែយល់ជាងប៉ាយភានជានទៅទៀត ។ ប៉ុន្តែគាត់ស្មានថាមាណពជិតអស់ស្នៀតហើយគោនទំប្រឹងបន្តិចក្រែងមានផ្លូវយកជ័យជំនះបាន, ទើរហើយគាត់ទំព្រាំទាំងពីរនាក់បងប្អូនវាយមួយស្នៀតហើយមួយស្នៀតទៀត ដោយចិញ្ចឹមបំណងអាក្រក់លាយផង ប៉ាយភានជានមិនហ៊ានបណ្តោយយូរខ្លាចតាចាស់ទាំងពីរមានរបៀបដែរក៏បញ្ចប់ស្នៀតក្បាច់ល្អនេះវាយសម្រុកយកជ័យដោយយាដាវសំដែងស្នៀតប្រាំត្រកូលទឹកត្រីដាវពាក់ព្រេក ៗ ទាំងពន្លឺព្រិច ៗ ។ នេះជាស្នៀតវិសេសបំផុតក្នុងចំណោមស្នៀតគ្មានដាវទាំងចិតសិបពីរខានក្រុមភ្នំទឹកកក ។

ស៊ុំផានមិនបង្អង់យូរអន្ទ្រូនកាំបិតមុខវិលសំដែងស្នៀតធ្លាក់ពីកមុខស្រួច ថែកសន្លឹកខ្យល់គ្រប់ទិសទី ។ ពុស្សូរអូយៗ ! គឺទំនងមិនហួសបីត្រឹវប្ហូសដៃ ទំនងមិនហួសប្អូនរបួសស្មារដោយសារកាំបិតកញ្ចាស់ ។ គេនាំបងប្អូនបង្វិលខ្លួនរត់ទៅក្រៅភ្លាម ។ ទំនងមិនហួសបីកញ្ចក់ទំនងកុងរត់ចូលព្រៃខាងកើត, ទំនងមិនហួសប្អូនរត់សំដៅព្រៃខាងលិច ។ ពេលនេះនៅសល់តែសាកសពសិស្សភ្នំទឹកកកនិងលោហិតក្រហមច្រាល ។

សិស្សភ្នំទឹកកកដែលនៅសល់សម្លឹងមើលមុខគ្នាឥតចេញស្តី, ប៉ាយភាន់ជានមើលមុខស៊ុំផានដោយឈឺចាប់ , អៀនខ្មាស , សង្ស័យនិងត្រេកអរជាពិសេស ព្រោះបើគ្មានស៊ុំផានចូលជួយទាន់ទេ , ពួកគាត់ច្បាស់ជាចោលសាច់ចោលឆ្អឹងលើកោះវៀននៅនេះហើយ ។ នឹកដល់អំពើអមនុស្សធម៌នៃបងប្អូនត្រកូលទំនងគាត់មិនទាន់បាត់ភ័យនៅឡើយ ។ (នៅមានត)

ចំពោះពុម្ពលេខ ៣២៨ ចុះថ្ងៃ ២៨-៩-៧០ ក្រសួងព័ត៌មានទី១ ចំនួន ២០០០ ច្បាប់

Khmer Story Lovers